00273343

C9/4/2

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 22 / 01 / 2009
ម៉ោង (Time/Heure): 13:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A.Fay

# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
# នៅចំពោះមុខអង្គបុរេជំនុំជម្រះ

**សំណុំរឿងលេខ៖** ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ១៣)

**កាលបរិច្ឆេទនៃការបញ្ជូន៖** ថ្ងៃទី២២ ខែមករា ឆ្នាំ២០០៩

**ភាគីបញ្ជូន៖** ការិយាល័យសហព្រះរាជអាជ្ញា

**ភាសាដើម៖** ភាសាអង់គ្លេស

**ប្រភេទឯកសារ៖** **អត្ថបទជាសាធារណៈបន្ទាប់ពីលុបខ្លឹមសារមួយចំនួន**

---

## ចម្លើយតបរបស់សហព្រះរាជអាជ្ញា នៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា ស្តីពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន

---

**បញ្ជូនដោយ៖**
**ការិយាល័យសហព្រះរាជអាជ្ញា៖**
លោកស្រី ជា លាង
លោក Robert PETIT
លោក យ៉េត ចរិយា
លោក William SMITH
លោក តាន់ សេណារ៉ុង
លោក Anees AHMED

**បញ្ជូនទៅ៖**
**អង្គបុរេជំនុំជម្រះ៖**
ចៅក្រម ប្រាក់ គីមសាន
ចៅក្រម Rowan DOWNING
ចៅក្រម ន៍យ ថុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

**មេធាវីការពារក្តីរបស់ នួន ជា៖**
លោក សុន អរុណ
លោក Michiel PESTMAN
លោក Victor KOPPE
លោក ម៉ម ចាន់ណា
លោក Andrew IANUZZI

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 23 / 01 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A.Fay

00273344

C9/4/2

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ១៣)

## ១. សេចក្តីផ្តើម

១. ជនត្រូវចោទ នួន ជា បានដាក់បណ្តឹងឧទ្ធរណ៍ ("បណ្តឹងឧទ្ធរណ៍")[1] ដែលតវ៉ាលើដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ដែលបានបន្តចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន របស់គាត់មានចិរវេលាបន្ថែម មិនលើសពីមួយឆ្នាំ ("ដីកាសម្រេចបន្តចិរវេលា")[2] ។ គាត់តវ៉ាថា (១) ការឃុំខ្លួនគាត់បន្ត មិនទទួលបានការគាំទ្រពីច្បាប់ ឬ អង្គហេតុឡើយ[3], (២) ដីកាសម្រេចបន្តចិរវេលា គឺមានវិការៈផ្នែកនីតិវិធី ដោយសារសហចៅក្រមស៊ើបអង្កេតមិនបានផ្តល់មូលហេតុនានាដើម្បីគាំទ្រការបន្តចិរវេលានេះ[4] និង (៣) មានអង្គហេតុនានាដើម្បីធ្វើជាយុត្តិកម្មសំរាប់ "ការឃុំខ្លួនក្នុងផ្ទះ" នៅមន្ទីរព្យាបាលសុខភាពណាមួយដែលបានអនុម័ត[5] ។

២. សហព្រះរាជអាជ្ញាស្នើឲ្យ អង្គបុរេជំនុំជម្រះបដិសេធចោលបណ្តឹងឧទ្ធរណ៍នេះ ដោយឈរលើទឡ្ហីករណ៍ដូចតទៅ៖

(ក) ដើមបណ្តឹងឧទ្ធរណ៍ ខកខានមិនបានបង្ហាញឲ្យឃើញអំពីការផ្លាស់ប្តូរកាលៈទេសៈជាក់ស្តែងណាមួយឡើយតាំងពីគាត់ត្រូវបានឃុំខ្លួនពីដំបូង ដោយសហចៅក្រមស៊ើបអង្កេត ("ដីកាបង្គាប់ឲ្យឃុំខ្លួន")[6] នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧ នោះមក និងតាំងពីការឃុំខ្លួនត្រូវបានសម្រេចយកតាមដោយអង្គបុរេជំនុំជម្រះ នៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៨ ("សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួន")[7] ។

---

[1] *ករណីរបស់ នួន ជា,* បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចបន្តថេរៈវេលានៃការឃុំខ្លួនបណ្តោះអាសន្ន, ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ ២០០៨, C9/4/1, ERN 00232728-00232736 [*ចាប់ពីនេះតទៅហៅថា* បណ្តឹងឧទ្ធរណ៍] ។

[2] *ករណីរបស់ នួន ជា,* ដីកាសម្រេចបន្តថេរៈវេលានៃការឃុំខ្លួនបណ្តោះអាសន្ន, ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៨, C9/3, ERN 00224203-00224204 [*ចាប់ពីនេះតទៅហៅថា* ដីកាសម្រេចបន្តថេរៈវេលា] ។

[3] បណ្តឹងឧទ្ធរណ៍, កថាខ័ណ្ឌទី១ ។

[4] បណ្តឹងឧទ្ធរណ៍, កថាខ័ណ្ឌទី១ ។

[5] បណ្តឹងឧទ្ធរណ៍, កថាខ័ណ្ឌទី២១ ។

[6] *ករណីរបស់ នួន ជា,* ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន, ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧, C9 [*ចាប់ពីនេះតទៅហៅថា* ដីកាបង្គាប់ឲ្យឃុំខ្លួន] ។

[7] *ករណីរបស់ នួន ជា,* សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ជនត្រូវចោទ នួន ជា, ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៨, C11/54, ERN 00172907-00172934 [*ចាប់ពីនេះតទៅហៅថា* សាលដីកាលើបណ្តឹងឧទ្ធរណ៍ឃុំខ្លួន នួន ជា] ។ ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា ស្តីពីការសុំពន្យារពេលការឃុំខ្លួនបណ្តោះអាសន្ន

(ខ) លក្ខខណ្ឌទាំងអស់ប្រាំដែលមានលក្ខណៈខុសៗគ្នា ដែលជាការចាំបាច់សម្រាប់ការឃុំខ្លួន នៅក្រោមវិធាន៦៦.៣.ខ នៃវិធានផ្ទៃក្នុង នៅតែបំពេញបាន ទាំងសម្រាប់បុគ្គលម្នាក់ៗ និងជារួម ។ សម្រាប់ចំណុចជាក់លាក់គឺថា ការឃុំខ្លួនជើមបណ្តឹងឧទ្ធរណ៍នៅតែជាវិធានការចាំបាច់ (១) ដើម្បីទប់ស្កាត់កុំឱ្យគាត់ដាក់ការគាបសង្កត់ទៅលើសាក្សី ឬជនរងគ្រោះ, (២) ដើម្បីថែរក្សាភស្តុតាង ឬការពារមិនឱ្យបំផ្លាញភស្តុតាង, (៣) ដើម្បីធានាអំពីវត្តមានរបស់គាត់នៅក្នុងដំណើរការនីតិវិធី, (៤) ដើម្បីការពារសន្តិសុខឱ្យខ្លួនគាត់ និង (៥) ដើម្បីរក្សាសណ្តាប់ធ្នាប់សាធារណៈ ។

(គ) ការឃុំខ្លួនក្នុងផ្ទះមិនបានអនុញ្ញាតឡើយ ដោយសារមន្ទីរឃុំឃាំងអ.វ.ត.ក មានបំពាក់នូវសម្ភារៈយ៉ាងសមស្រប ដើម្បីថែទាំសុខភាពក្នុងករណីសង្គ្រោះបន្ទាន់ ហើយទោះក្នុងព្រឹត្តិការណ៍ណាក៏ដោយ ស្ថានភាពសុខភាពរបស់ដើមបណ្តឹងឧទ្ធរណ៍ ក៏មិនអាចជាធ្វើយុត្តិកម្ម សម្រាប់ការកែសម្រួលណាមួយទៅលើលក្ខខណ្ឌនៃការឃុំខ្លួនគាត់បានឡើយ ។

## ២. សេចក្តីសន្និដ្ឋានបឋម

***សវនាការផ្ទាល់មិនចាំបាច់ទេ***

៣. វិធាន៧៧.៣ នៃវិធានផ្ទៃក្នុង (“វិធាន”) អនុញ្ញាតឱ្យអង្គបុរេជំនុំជម្រះ ដើម្បីកំណត់ទៅលើបណ្តឹងឧទ្ធរណ៍ ដោយផ្អែកលើសេចក្តីសន្និដ្ឋានជាលាយលក្ខអក្សរតែមួយមុខប៉ុណ្ណោះ បន្ទាប់ពីបានពិចារណាទៅលើទស្សនៈផ្សេងៗរបស់ភាគីរួចមក ។ ដើមបណ្តឹងឧទ្ធរណ៍ មិនបានសុំឱ្យមានសវនាការផ្ទាល់មាត់ចំពោះបណ្តឹងឧទ្ធរណ៍នេះទេ ។ ក្នុងខណៈដែលអង្គបុរេជំនុំជម្រះបានស្តាប់សវនាការផ្ទាល់មាត់លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនបណ្តោះអាសន្ន ដ៏មានសារៈសំខាន់នានាហើយនោះ បណ្តឹងឧទ្ធរណ៍នេះ ដែលជាការព្រួយបារម្ភតែចំពោះការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នពីមុន មិនមានការលើកឡើងនូវសេចក្តីអះអាងផ្អែកអង្គហេតុ និងអង្គច្បាប់ថ្មីៗនោះទេ ដែលជាតម្រូវការចាំបាច់ ត្រូវលើកនៅក្នុងសវនាការផ្ទាល់មាត់នោះ ។

អំណះអំណាងភាគច្រើនដែលបានលើកនៅក្នុងបណ្តឹងឧទ្ធរណ៍ ត្រូវបានគេពិចារណារួចហើយនៅក្នុងដំណើរការនីតិវិធីកាលពីលើកមុន នៅចំពោះមុខតុលាការនេះ ទាក់ទិននឹងភាគីដដែល ។ ហេតុដូចនេះ ដើម្បីជាប្រយោជន៍នៃសេដ្ឋកិច្ចរបស់តុលាការ សូមសន្និដ្ឋានថា បណ្តឹងឧទ្ធរណ៍នេះ គួរតែត្រូវបានកំណត់សម្រេច ទៅលើតែសេចក្តីសន្និដ្ឋានជាលាយលក្ខអក្សរ តែមួយមុខប៉ុណ្ណោះ ។

## ៣. ច្បាប់

### *ភារកិច្ចដើម្បីផ្តល់សំអាងហេតុនៅក្នុងដីកាបង្គាប់ឲ្យឃុំខ្លួន*

៤. វិធាន៦៣.៧ នៃវិធានផ្ទៃក្នុង តម្រូវថា ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត អំពីការបន្តថិរវេលានៃការឃុំខ្លួន "ត្រូវមានសំអាងហេតុចំពោះការពន្យារពេលនៃការឃុំខ្លួន" ។ ការផ្តល់សំអាងហេតុដូច្នេះ ត្រូវតែបានធ្វើឡើងបន្ទាប់ពីបានពិចារណាទៅលើការតវ៉ារបស់ជនជាប់ឃុំ ។ ដោយលើកយោងនូវករណីយុត្តិសាស្ត្រអន្តរជាតិនានាដែលគេបានធ្វើការដោះស្រាយចប់សព្វគ្រប់ហើយនោះ អង្គបុរេជំនុំជម្រះក៏បានរកឃើញថា ដីកាសម្រេចទាំងអស់របស់ស្ថាប័នតុលាការនេះ រួមទាំងសហចៅក្រមស៊ើបអង្កេតផង ត្រូវតែផ្តល់សំអាងហេតុដើម្បីបំពេញតាមបទដ្ឋានអន្តរជាតិ[8] ។

៥. សិទ្ធិអំណាចរបស់តុលាការ "ត្រូវតែបង្ហាញ តាមរយៈកិច្ចពិភាក្សាអំពីកត្តាផ្សេងៗទាំងអស់" នូវរបៀបដែលចុងចោទបានបំពេញ ឬខកខានមិនបានជំរះនូវបន្ទុករបស់ខ្លួន ដែលថាគាត់នឹងចូលបង្ហាញខ្លួនចំពោះសវនាការ និងដែលមិនធ្វើឲ្យមានគ្រោះថ្នាក់ចំពោះជនរងគ្រោះ សាក្សី ឬ

[8] *ករណីរបស់ នួន ជា,* សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងចំពោះដីកាបដិសេធពាក្យសុំមោឃភាព, សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ០៦), ចុះថ្ងៃទី២៨ សីហា ឆ្នាំ២០០៨, ERN 001219322-00219333, D55/I/8, កថាខ័ណ្ឌទី២១ ។

តតីយជនណាម្នាក់ឡើយ[9] ។ ស្ថាប័នតុលាការមួយមិនជាប់កាតព្វកិច្ច ត្រូវដោះស្រាយកត្តាទាំងអស់ដែលអាចមាន ដែលគេអាចយកមកពិចារណានៅពេលធ្វើការសម្រេចចិត្តថាតើ ចុងចោទនឹងចូលបង្ហាញខ្លួនចំពោះសវនាការនោះទេ ។ ដើម្បីឱ្យមានលក្ខណៈគ្រប់គ្រាន់ គេត្រូវបង្ហាញកត្តាពាក់ព័ន្ធទាំងអស់ ដែលត្រូវយកចិត្តទុកដាក់ធ្វើឱ្យសម្រេចបានចំពោះសេចក្ដីសម្រេចរបស់ខ្លួន ។ បើនិយាយតាមរបៀបផ្សេងពីនេះ សិទ្ធិអំណាច "ត្រូវតែជាមតិយោបល់ផ្សេងៗដែលមានសំអាងហេតុ"[10] ។

## *លក្ខខណ្ឌចាំបាច់សម្រាប់ការឃុំខ្លួន*

៦. នៅក្រោមវិធាន៦៣.៣ នៃវិធានផ្ទៃក្នុង សហចៅក្រមស៊ើបអង្កេតអាចចេញដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នបាន ប្រសិនបើ៖

(ក) មានមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថា ចុងចោទធ្លាប់បានប្រព្រឹត្តិបទល្មើស ដូចមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ។

(ខ) សហចៅក្រមស៊ើបអង្កេតយល់ឃើញថា ការឃុំខ្លួនបណ្ដោះអាសន្ន គឺជាវិធានការចាំបាច់ដើម្បី៖

(១) រារាំងកុំឱ្យចុងចោទនោះគាបសង្កត់ទៅលើសាក្សី ឬ ជនរងគ្រោះ រារាំងកុំឱ្យមានការត្រូវរ៉ូវគ្នារវាងចុងចោទរូបនោះ និងអ្នកសមគំនិតរបស់ជននោះ ។

---

[9] *វ្គអាជ្ញា ទល់នឹង Popovic,* សេចក្ដីសំរេចពីបណ្ដឹងឧទ្ធរណ៍លើបញ្ហាបន្ទាន់បន្ទំរបស់សាលាដំបូង ដែលសំរេចបដិសេធសេចក្ដីស្នើសុំឱ្យមានការដោះលែងជាបណ្ដោះអាសន្នរបស់ Ljubomir Borovcanin, ករណីលេខ IT-05-88-AR65.2, អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី៣០ មិថុនា ២០០៦, កថាខ័ណ្ឌទី៨ [*ចាប់ពីនេះតទៅហៅថា* សេចក្ដីសម្រេចរបស់ Popovic] ។

[10] *វ្គអាជ្ញា ទល់នឹង Haradinaj* សេចក្ដីសម្រេចលើញត្តិសុំឱ្យដោះលែងជាបណ្ដោះអាសន្នរបស់ Lahi Brahimaj ករណីលេខ IT-04-84-PT, អង្គជំនុំជម្រះសាលាដំបូង ICTY, ចុះថ្ងៃទី០៣ ឧសភា ២០០៦ កថាខណ្ឌទី១៦ ។

(២) ថែរក្សាភស្តុតាង ឬ ការពារមិនឱ្យមានការបំផ្លាញភស្តុតាង ។

(៣) ធានាអំពីវត្តមានរបស់ចុងចោទនៅក្នុងដំណើរការនីតិវិធី

(៤) ការពារសន្តិសុខឱ្យចុងចោទ ឬ

(៥) រក្សាសណ្តាប់ធ្នាប់សាធារណៈ ។

៧. ទឡ្ហីករណ៍ទាំងប្រាំ នៅក្រោមវិធាន៦៣.៣.ខ នៃវិធានផ្ទៃក្នុង គឺខុសដាច់ដោយឡែកពីគ្នា[11] ។ មិនមានលក្ខខណ្ឌណាមួយ ដែលតម្រូវឱ្យសហចៅក្រមស៊ើបអង្កេត ត្រូវតែរកឱ្យឃើញថា គ្រប់ទឡ្ហីករណ៍នីមួយៗត្រូវតែបានបំពេញមុននឹងពិចារណាថា ការឃុំខ្លួនគឺជាវិធានការចាំបាច់ ឬថា ការបន្តថិរវេលារបស់ខ្លួន ត្រូវបានអនុញ្ញាតនោះឡើយ ។ ផ្ទុយមកវិញ បើសិនសហចៅក្រមស៊ើបអង្កេតបានពិចារណាឃើញថា មានទឡ្ហីករណ៍មួយក្នុងចំណោមទឡ្ហីករណ៍ទាំងប្រាំ នោះការសាកល្បងសម្រាប់ការឃុំខ្លួន ក៏ត្រូវបានបំពេញហើយ ។ យុទ្ធវិធីបែបនេះ ក៏ត្រូវបានអនុវត្តតាមផងដែរដោយតុលាការព្រហ្មទណ្ឌអន្តរជាតិដទៃទៀត ដែលមានការពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋធ្ងន់ធ្ងរជាអន្តរជាតិស្រដៀងគ្នានេះ[12] ។

## *ការប្រើប្រាស់ឆន្ទានុសិទ្ធិក្នុងការពិចារណាលើការឃុំខ្លួន*

---

[11] សាលដីកាលើបណ្តឹងឧទ្ធរណ៍ឃុំខ្លួន អៀង សារី, កថាខ័ណ្ឌទី១២១ ។

[12] *ព្រះរាជអាជ្ញា ទល់នឹង Sainovic និង Odjanic,* សេចក្តីសំរេចដែលបដិសេធសំណើប្តឹងឧទ្ធរណ៍របស់ Odjanic ករណីលេខ IT-99-37-AR65.2, អង្គជំនុំជម្រះសាលាដំបូង ICTY, ចុះថ្ងៃទី២៧ មិថុនា ២០០៣, ទំព័រ៣, ERN 00154039-42 និងដែលបានយកមកអនុវត្តដោយ អ.វ.ត.ក/អ.ប.ជ: *សហព្រះរាជអាជ្ញា ទល់នឹង កាំង ហ្គេចអ៊ាវ ហៅ "ឌុច",* សាលដីកាលើបណ្តឹង ឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ជនត្រូវចោទ កាំង ហ្គេចអ៊ាវ ហៅ "ឌុច", សំណុំរឿងលេខ: ០០១/១៨-០៧-២០០៧/អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ០១), ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៧, ERN 00154284-00154302, C5 / 45, កថាខ័ណ្ឌទី៥៩, [*ចាប់ពីនេះតទៅហៅថា* សាលដីកាលើបណ្តឹងឧទ្ធរណ៍ឃុំខ្លួន ឌុច] ។

៨. អង្គជំនុំជម្រះមួយ មានឆន្ទានុសិទ្ធិទៅលើរបៀបដែលគេធ្វើការសន្និដ្ឋានចុងក្រោយដែលថា ការឃុំខ្លួន គឺជាវិធានការចាំបាច់ ឬការបន្តថិរវេលានៃការឃុំខ្លួន ត្រូវបានអនុញ្ញាត ។ ឆន្ទានិសិទ្ធិបែបនេះ ជាធម្មតាត្រូវបានគេប្រើនៅពេលណាមានការពិចារណាទៅលើឯកសារទាំងអស់ នៅលើសំណុំរឿង និងអង្គហេតុនៃរឿងក្ដីដែលពាក់ព័ន្ធទាំងអស់ រួមទាំងស្ថានទម្ងន់នៃបទចោទប្រកាន់ ភាពសមហេតុសមផលនៃភស្តុតាង ចរិតលក្ខណៈ និងឥរិយាបថអតីតកាល និងបច្ចុប្បន្នកាលរបស់ចុងចោទ ផលប្រយោជន៍របស់សាក្សី និងជនរងគ្រោះ និងផលប្រយោជន៍នៃយុត្តិធម៌ជារួម[13] ។ ការណ៍នេះ វាស្របនឹងទម្លាប់នៃការអនុវត្តន៍ដែលអាចទទួលយកបាន នៅតាមបណ្ដាតុលាការព្រហ្មទណ្ឌអន្តរជាតិនានា និងត្រូវបានយកតាមដោយតុលាការនេះ[14] ។

៩. វិធានផ្ទៃក្នុងតម្រូវថា សហចៅក្រមស៊ើបអង្កេតត្រូវ "ពិចារណា" ថា ទឡ្ហីករណ៍នៃការឃុំខ្លួនបណ្ដោះអាសន្នត្រូវបានបំពេញ ។ មិនមានលក្ខខណ្ឌតម្រូវឱ្យបង្ហាញភស្តុតាងអំពីអត្ថិភាពនៃទឡ្ហីករណ៍ណាមួយក្នុងចំណោមទឡ្ហីករណ៍ទាំងនោះ ឱ្យហួសពីវិមតិសង្ស័យនោះឡើយ ហើយសូម្បីតែតុល្យការនៃភវនីយភាពក៏គ្មានដែរ ។ ទោះបីចុងចោទបានធ្វើឱ្យរំលត់ចំពោះបន្ទុករបស់ខ្លួនទាំងស្រុង ទាក់ទិននឹងទឡ្ហីករណ៍នីមួយៗនៃការឃុំខ្លួនក៏ដោយ ក៏គាត់នៅតែត្រូវជំរះចំពោះសហចៅក្រមស៊ើបអង្កេតដែលថា សហចៅក្រមស៊ើបអង្កេតគួរតែប្រើប្រាស់ឆន្ទានុសិទ្ធិរបស់គេ ដើម្បីសម្រេចដោះលែង ដោយមានការគិតគូរទៅលើគ្រប់កាលៈទេសៈទាំងអស់[15] ។

## ***ការបន្តថិរវេលានៃការឃុំខ្លួន***

---

[13] *រដ្ឋអាជ្ញា ទល់នឹង Ljube Boskoski និង Johan Tarculovski* សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ពីបញ្ហាបន្ទាន់បន្ទំ របស់ Johan Tarculovski ស្ដីពីការដោះលែងជាបណ្ដោះអាសន្ន ករណីលេខ IT-04-82-AR65.4, អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ICTY, ចុះថ្ងៃទី ២៧ កក្កដា ២០០៧ កថាខណ្ឌទី៥, ERN 00153946-54 ។

[14] សាលដីកាលើបណ្ដឹងឧទ្ធរណ៍ឃុំខ្លួន ឌុច, កថាខ័ណ្ឌទី២៧ ។

[15] *រដ្ឋអាជ្ញា ទល់នឹង Dragomir Milosevic,* សេចក្ដីសំរេចលើញត្តិស្នើសុំឱ្យដោះលែងបណ្ដោះអាសន្នរបស់មេធាវីការពារក្ដី ករណីលេខ IT-98-29-I/PT, អង្គជំនុំជម្រះសាលាដំបូង ICTY, ចុះថ្ងៃទី១៣ កក្កដា ២០០៥, កថាខណ្ឌទី៥ ។

00273350

C9/4/2



១០. វិធាន៦៣.៦ នៃវិធានផ្ទៃក្នុង ចែងឲ្យមានការពិនិត្យឡើងវិញម្តងម្កាលដោយស្វ័យប្រវត្តិទៅលើការឃុំខ្លួនចុងចោទ ។ បទប្បញ្ញត្តិដូចនេះ ពុំមានទេនៅក្នុងឯកសារជាមូលដ្ឋានរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសំរាប់អតីតយូហ្គោស្លាវី (“ICTY”) ប្រទេសរវ៉ាន់ដា (“ICTR”) និងតុលាការពិសេសសម្រាប់សៀរ៉ាឡេអូន (“SCSL”) ។ ទោះជាយ៉ាងណាក្តី តុលាការ*ពិសេស* ទាំងអស់នេះ នៅតែប្រកាន់ខ្ជាប់ថា សម្រាប់ពាក្យសុំបន្តការដោះលែងទទួលបានជោគជ័យ ចុងចោទត្រូវតែបង្ហាញឲ្យឃើញថាមាន “ការផ្លាស់ប្តូរជាក់ស្តែងណាមួយអំពីកាលៈទេសៈ”[16] ។

១១. ស្រដៀងគ្នានឹងវិធានផ្ទៃក្នុងនៃតុលាការនេះដែរ វិធាន១១៨ នៃវិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ (“ICC”) តម្រូវថា ការឃុំខ្លួនចុងចោទមុនពេលសវនាការត្រូវមានការត្រួតពិនិត្យឡើងវិញដោយអង្គបុរេជំនុំជម្រះនៃតុលាការនេះ នៅរៀងរាល់១២០ថ្ងៃម្តង ។ អង្គបុរេជំនុំជម្រះនៃតុលាការ ICC មាន “កាតព្វកិច្ចឯករាជ្យ និងខុសប្លែកពីគេ [...] ដើម្បីធានាថា ជននោះមិនត្រូវបានគេឃុំខ្លួនក្នុងថិរវេលាមួយដោយមិនសមហេតុផលនៅមុនពេលសវនាការឡើយ”[17] ។ អង្គបុរេជំនុំជម្រះអាចកែសម្រួលលើសេចក្តីសម្រេចរបស់ខ្លួនស្តីពីការឃុំខ្លួនបាន “ប្រសិនបើ ខ្លួនពេញចិត្តចំពោះការផ្លាស់ប្តូរនៅក្នុងកាលៈទេសៈ ដែលតម្រូវឲ្យធ្វើដូច្នេះ”[18] ។ នៅតុលាការ ICC “អយ្យការមានបន្ទុកភស្តុតាងទាក់ទងនឹងអត្ថិភាពដែលចេះតែមានជាបន្តបន្ទាប់អំពីលក្ខខណ្ឌផ្សេងៗ [...] អំពីការឃុំខ្លួននៅមុនពេលសវនាការ”[19] ។

---

[16] *រដ្ឋអាជ្ញា ទល់នឹង Boskoski និង Tarculovski,* ករណីលេខ IT-04-82-PT, សេចក្តីសម្រេចទាក់ទិននឹងញត្តិបន្តស្នើសុំការដោះលែងបណ្តោះអាសន្ន Johan Tarculovski, ចុះថ្ងៃទី១៧ មករា ២០០៧ កថាខណ្ឌទី៩ ។

[17] ស្ថានភាពនៅក្នុងសាធារណៈរដ្ឋប្រជាធិបតេយ្យកុងហ្គោ ក្នុងករណី រដ្ឋអាជ្ញា ទល់នឹង Germaine Katanga និង Mathieu Ngudjolo Chui, សេចក្តីសំរេចទាក់ទងនឹងការសង្កេតទៅលើការពិនិត្យឡើងវិញនៃការឃុំខ្លួនមុនសវនាការ លើឈ្មោះ Germaine Katanga, ករណីលេខ ICC-01/04-01/07, អង្គបុរេជំនុំជម្រះ, ចុះថ្ងៃទី៩ កក្កដា ២០០៨, ទំព័រ៤ ។

[18] ស្ថានភាពនៅក្នុងសាធារណៈរដ្ឋប្រជាធិបតេយ្យកុងហ្គោ ក្នុងករណី រដ្ឋអាជ្ញា ទល់នឹង Germaine Katanga និង Mathieu Ngudjolo Chui, ការពិនិត្យឡើងវិញលើសេចក្តីសម្រេចលើលក្ខខណ្ឌនៃការឃុំខ្លួនមុនសវនាការ លើឈ្មោះ Germaine Katanga, ករណីលេខ ICC-01/04-01/07, អង្គបុរេជំនុំជម្រះ, ចុះថ្ងៃទី១៨ សីហា ២០០៨, ទំព័រ៦ ។

[19] ស្ថានភាពនៅក្នុងសាធារណៈរដ្ឋប្រជាធិបតេយ្យកុងហ្គោ ក្នុងករណី រដ្ឋអាជ្ញា ទល់នឹង Germaine Katanga និង Mathieu Ngudjolo Chui, សេចក្តីសំរេចទាក់ទងនឹងការសង្កេតទៅលើការពិនិត្យឡើងវិញនៃការឃុំខ្លួនមុនសវនាការ លើឈ្មោះ Germaine Katanga, ករណីលេខ ICC-01/04-01/07, អង្គបុរេជំនុំជម្រះ, ចុះថ្ងៃទី៩ កក្កដា ២០០៨, ទំព័រ៤ ។

១២. នៅចំពោះមុខតុលាការនេះ វិធានផ្ទៃក្នុងមិនបានចែងឲ្យមានការស្តាប់សវនាការរបស់ព្រះរាជអាជ្ញា ឬភាគីណាមួយផ្សេងទៀតឡើយ នៅក្នុងខណៈធ្វើការកំណត់សម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួននោះ[20] ។ វិធានមានចែងតែអំពីការជំទាស់តវ៉ាដែលត្រូវដាក់ដោយចុងចោទតែប៉ុណ្ណោះ[21] ។ អាស្រ័យហេតុនេះហើយបានជាវិធាននានា ដាក់បន្ទុកបន្ថែមទៅលើសហចៅក្រមស៊ើបអង្កេត ដើម្បីផ្តល់យុត្តិកម្មតាមរយៈសេចក្តីសម្រេចដែលមានសំអាងហេតុ ដែលថាលក្ខខណ្ឌនានានៃការឃុំខ្លួននៅតែបន្តត្រូវបានបំពេញនៅក្រោមវិធាន៦៣.៣ ដើម្បីអនុញ្ញាតឲ្យមានការបន្តថិរវេលា ។

## *ការឃុំខ្លួនក្នុងផ្ទះ*

១៣. វិធានផ្ទៃក្នុងមិនមានចែងអំពីទម្រង់ណាផ្សេងនៃការឃុំខ្លួនឡើយ[22] ។ ប៉ុន្តែវិធាន៦៥.១ គិតទុកជាមុនថា ចុងចោទអាចត្រូវបានដោះលែងពីមន្ទីរឃុំឃាំង តាមរយៈដីកាសម្រេចឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ ក្រោមលក្ខខណ្ឌនានាដែលចាំបាច់ ដើម្បីធានាអំពីវត្តមានរបស់ជននោះនៅក្នុងដំណើរការនីតិវិធី និងការការពារអ្នកដទៃ[23] ។ ប៉ុន្តែបើសិនមានលក្ខខណ្ឌណាមួយដែលចាំបាច់ឲ្យមានការឃុំខ្លួនត្រូវបានបំពេញ ក្រោមវិធាន៦៣.៣.ខ នោះចុងចោទមិនអាចត្រូវបានដោះលែង តាម ដីកាសម្រេចឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការបានឡើយ[24] ។

---

[20] វិធាន៦៣.៧ នៃវិធានផ្ទៃក្នុង [*ចាប់ពីនេះតទៅហៅថា* វិធាន] ។

[21] វិធាន៦៣.៧ នៃវិធានផ្ទៃក្នុង ។

[22] *ករណីរបស់ អៀង សារី,* សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ជនត្រូវចោទ អៀង សារី, សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ០៣), ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៨, ERN 00232830-00232861, C22/I/73, កថាខ័ណ្ឌទី១១៩ [សាលដីកាលើបណ្តឹងឧទ្ធរណ៍ឃុំខ្លួន អៀង សារី] ។

[23] សាលដីកាលើបណ្តឹងឧទ្ធរណ៍ឃុំខ្លួន អៀង សារី, កថាខ័ណ្ឌទី១២០ ។

[24] សាលដីកាលើបណ្តឹងឧទ្ធរណ៍ឃុំខ្លួន អៀង សារី, កថាខ័ណ្ឌទី១២១ ។

១៤. ទោះបីចុងចោទ ត្រូវបានដាក់ឱ្យជាប់ឃុំក្នុងផ្ទះ ឬ "ការឃុំខ្លួនក្នុងមន្ទីរពេទ្យ" ក៏ដោយ ក៏នៅតែមានហានិភ័យយ៉ាងខ្ពស់ចំពោះសុវត្ថិភាពផ្ទាល់ខ្លួនរបស់ជននោះដែរ ។ គាត់នៅតែតម្រូវឱ្យចូលមកកាន់ទីតាំងនិវាសនដ្ឋាន អ.វ.ត.ក ជាដដែលទេ ទៅតាមឱកាសខុសៗគ្នា ហើយវានឹងមានលំបាកក្នុងការធានាចំពោះសុវត្ថិភាពរបស់គាត់ នៅក្នុងអម្លុងពេលនៃការដឹកជញ្ជូនពីមន្ទីរពេទ្យ ឬពីផ្ទះរបស់គាត់មក អ.វ.ត.ក ដើម្បីចូលរួមផ្ទាល់នៅក្នុងសវនាការសាធារណៈនានាដែលបានកំណត់ពេលវេលារួចហើយនោះ[25] ។

## *ការឃាត់ខ្លួននៅក្នុងលំនៅដ្ឋាន*

១៥. ច្បាប់លក្ខន្តិកៈ ឬវិធាននៃនីតិវិធីរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិនានាមិនបានចែងអំពី "ការឃាត់ខ្លួននៅក្នុងលំនៅដ្ឋាននោះទេ" ។ តុលាការ ICTY បានពិនិត្យពិចារណាដោយប្រុងប្រយ័ត្ន ចំពោះសំណើសុំបែបនេះ ។ នៅក្នុងករណីរបស់ *Blaskic* តុលាការនេះបានផ្តល់ការអនុញ្ញាតលើសំណើមួយដែលស្នើសុំឱ្យធ្វើការឃុំខ្លួននៅក្នុងផ្ទះមួយដែលមានសុវត្ថិភាពដោយសារមូលហេតុថា ជនជាប់ចោទបានបំពេញគ្រប់តាមលក្ខខណ្ឌតម្រូវជាមុនសម្រាប់ការដោះលែងជាបណ្តោះអាសន្នហើយ ថារូបគាត់បានយល់ព្រមចូលខ្លួនដោយស្ម័គ្រចិត្តចំពោះមុខតុលាការនៅក្នុងពេលដែលប្រទេសនេះ (ប្រទេសក្រូអាស៊ី) មិនអាចធ្វើការចាប់ខ្លួន ឬធ្វើបត្យាប័នរូបគាត់តាមផ្លូវច្បាប់បាន និងថា គាត់បានស្ម័គ្រចិត្តក្នុងការចេញចំណាយគ្រប់បែបយ៉ាងទាំងអស់ក្នុងការឃុំខ្លួនគាត់នៅក្នុងផ្ទះសុវត្ថិភាពនេះ[26] ។ នៅក្នុងករណីរបស់ *PLavsic* ជាជនជាប់ចោទ បានស្នើសុំឱ្យធ្វើការឃុំខ្លួននៅក្នុងផ្ទះមួយដែលមានសុវត្ថិភាពមួយ ដោយទាមទារថា អង្គភាពមន្ទីរឃុំឃាំងរៀបចំផែនការនិងទទួលថែរក្សាជនជាប់ឃុំដែលជាស្ត្រីមិនបានគ្រប់គ្រាន់នោះទេ ។ បន្ទាប់មកអ្នកស្រីក៏បានដកសំណើរបស់គាត់ដែលស្នើសុំឱ្យគេឃុំខ្លួននៅខាងក្រៅអង្គភាពមន្ទីរឃុំឃាំងវិញជាជំនួសដោយការកែប្រែស្ថានភាពខាងក្នុងរង្វង់អង្គភាព

---

[25] សាលដីកាលើបណ្តឹងឧទ្ធរណ៍ឃុំខ្លួន អៀង សារី, កថាខ័ណ្ឌទី១២២ ។

[26] *ករណីរបស់ រដ្ឋអាជ្ញា ទល់នឹង Blaskic*, សេចក្តីសម្រេចលើញត្តិតវ៉ារបស់មេធាវីការពារក្តី ដែលបានដាក់ជូន អនុលោមតាមវិធាន៦៤ នៃវិធានស្តីពីនីតិវិធី និងភស្តុតាង, សំណុំរឿងលេខ IT-94-14-T, 43, ចុះកាលបរិច្ឆេទខែមេសា ឆ្នាំ១៩៩៦, កថាខណ្ឌទី១៣-១៤ ។ ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា ស្តីពីការសុំពន្យារពេលការឃុំខ្លួនបណ្តោះអាសន្ន

មន្ទីរឃុំឃាំង[27] ។ លិខិតុបករណ៍ជាមូលដ្ឋានរបស់តុលាការ ICTY ជាសំខាន់គឺមិនអនុញ្ញាតឱ្យឃុំឃាំងជនជាប់ចោទនៅក្នុងលំនៅដ្ឋានឯកជនណាមួយដាច់តែឯងដែលស្នើឡើងដោយជនជាប់ចោទនោះទេ[28] ។

## ៤. អង្គហេតុ និងឧបត្ថម្ភករណ៍ផ្សេងៗ

### ក. បណ្តឹងឧទ្ធរណ៍មិនបង្ហាញអត្តសញ្ញាណនៃការប្រែប្រួលខាងសម្ភារៈនៃកាលៈទេសៈ ដើម្បីធ្វើយុត្តិកម្មលើការពិចារណាឡើងវិញនោះទេ

១៦. ដើមបណ្តឹងឧទ្ធរណ៍មិនបានបង្ហាញអត្តសញ្ញាណអំពីការប្រែប្រួលណាមួយខាងសម្ភារៈនៃកាលៈទេសៈ ដើម្បីឱ្យឃើញពីភាពចាំបាច់ដែលត្រូវធ្វើការពិនិត្យពិចារណាឡើងវិញទៅលើការឃុំខ្លួនរបស់គាត់នោះទេ ។ នៅពេលដែលរយៈពេលដែលស្ថិតនៅក្នុងទីឃុំឃាំងត្រូវបានតុលាការអន្តរជាតិនានាចាត់ទុកថាជាកត្តាដែលពាក់ព័ន្ធនោះ[29] ដើមបណ្តឹងឧទ្ធរណ៍មិនបានបង្ហាញឱ្យឃើញថា តើធ្វើដូចម្តេចដើម្បីអាចឱ្យធ្វើយុត្តិកម្មនូវការពិនិត្យពិចារណាឡើងវិញអំពីការឃុំខ្លួន[30]លើការរយៈពេលនិងការឃុំខ្លួនដោយផ្ទាល់បាន ។

១៧. នៅក្នុងសាលដីកាស្តីពីបន្តចិរៈវេលា(នៃការឃុំខ្លួន) របស់ខ្លួនដែលត្រូវបានតវ៉ាដោយសង្ស័យ (ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៨) សហចៅក្រមស៊ើបអង្កេត បានកត់សំគាល់ថា ការមាន

---

[27] *ករណីរបស់ រដ្ឋអាជ្ញា ទល់នឹង Halilovic* , ដីកាបង្គាប់របស់ប្រធានស្តីពីការបន្តសារឡើងវិញជាថ្មីនូវញត្តិតវ៉ារបស់មេធាវីការពារក្តីទាក់ទងទៅនឹងលក្ខខណ្ឌនៃការឃុំខ្លួននៅក្នុងអឡុងពេលសវនាការជំនុំជម្រះក្តី, សំណុំរឿងលេខ 1 IT-01-48-PT, ប្រធានតុលាការ ICTY, ចុះថ្ងៃទី២៤ មករា ឆ្នាំ២០០៥, កឋាខណ្ឌទី១៨ និងទី២៣ ។

[28] *ករណីរបស់ រដ្ឋអាជ្ញា ទល់នឹង Ljubicic*, សេចក្តីសម្រេចស្តីពីសំណើសុំកែប្រែលក្ខខណ្ឌនៃការឃុំខ្លួន, សំណុំរឿងលេខ IT-00-41-PT, ប្រធានតុលាការ ICTY, ចុះថ្ងៃទី២៣ វិច្ឆិកា ឆ្នាំ២០០៥, កឋាខណ្ឌទី៣ ។

[29] ស្ថានភាពនៅក្នុងសាធារណៈរដ្ឋប្រជាធិបតេយ្យកុងហ្គោ នៅកនុងករណីរបស់រដ្ឋអាជ្ញា ទល់នឹង Germain Katanga និង Mathieu Ngudjolo Chui, ការពិនិត្យឡើងវិញលើសេចក្តីសម្រេចស្តីពីការដាក់ពាក្យសុំដោះលែងឈ្មោះ Mathieu Ngudjolo Chui, សំណុំរឿងលេខ 01/04-01/07, របស់អង្គបុរេជំនុំជម្រះនៃតុលាការ ICC ចុះថ្ងៃទី២៣ កក្កដា ឆ្នាំ២០០៨, ទំព័រ១២ ។

[30] បណ្តឹងឧទ្ធរណ៍, កឋាខណ្ឌទី១៦ ។

មូលហេតុដែលត្រូវបានរកឃើញយ៉ាងច្បាស់លាស់ នៅតែមានអត្ថិភាពជាបន្តទៅទៀតដែលគួរឱ្យពួកគាត់ជឿជាក់ថា ដើមបណ្តឹងឧទ្ធរណ៍អាចបានប្រព្រឹត្តអំពើឧក្រិដ្ឋផ្សេងៗដូចដែលបានលើកឡើងនៅក្នុងដីកាបញ្ជូនរឿងឱ្យស៊ើបសួរ ។ សហចៅក្រមស៊ើបអង្កេត បានរំឭកឡើងវិញថា កិច្ចស៊ើបសួរមានការជឿនលឿនចាប់តាំងពីពេលនោះមក ហើយភស្តុតាងថ្មី ជាពិសេសដែលមកពីសំណុំរឿងលេខ០០១ ដែលបានទទួលមកបានបញ្ជាក់អំពីតួនាទីរបស់ដើមបណ្តឹងឧទ្ធរណ៍នៅក្នុងឧក្រិដ្ឋកម្មទាំងឡាយដែលបានចោទប្រកាន់ ។ សហចៅក្រមស៊ើបអង្កេត ក៏បានកត់សំគាល់ផងដែរ លក្ខខណ្ឌសម្រាប់ការឃុំខ្លួនដើមបណ្តឹងឧទ្ធរណ៍ក្រោមវិធាន ៦៣.៦.ខ នៃវិធានផ្ទៃក្នុង បានបន្តបំពេញគ្រប់គ្រាន់ហើយ ។ អាស្រ័យហេតុនេះ សហចៅក្រមស៊ើបអង្កេត បានបន្តថិរវេលានៃការឃុំខ្លួនរបស់គាត់ក្នុងរយៈមិនឱ្យលើសពី ១ឆ្នាំទៀត[31]។

១៨. វិធាន៦៣.៧ នៃវិធានផ្ទៃក្នុង តម្រូវឱ្យសហចៅក្រមស៊ើបអង្កេត "បញ្ជាក់ពីមូលហេតុ" ក្នុងការបន្តថិរវេលានៃការឃុំខ្លួននេះ ។ ភារកិច្ចរបស់សហចៅក្រមស៊ើបអង្កេត ក្នុងការផ្តល់មូលហេតុ កើតចេញមកពីគ្រោងការណ៍នៃដំណើរការបន្តថិរវេលា ។ អនុលោមតាមវិធាន ៦៣.៧ នៃវិធានផ្ទៃក្នុង ដំណើរការនៃនីតិវិធីក្នុងការបន្តថិរវេលា(នៃការឃុំខ្លួន) គឺកើតមានឡើងរវាងតែសហចៅក្រមស៊ើបអង្កេតហើយនិងជនត្រូវចោទគត់តែប៉ុណ្ណោះ ។ មុនពេលធ្វើការបន្តថិរវេលានៃការឃុំខ្លួន សហចៅក្រមស៊ើបអង្កេត បានធ្វើសវនាការតែលើការជំទាស់របស់ជនត្រូវចោទតែប៉ុណ្ណោះ ។ គ្មានភាគីណាផ្សេងទៀត (រួមទាំងសហព្រះរាជអាជ្ញាផង) ត្រូវបានធ្វើសវនាការ ឬចូលរួមនៅក្នុងដំណើរការនេះទេ ។ ដំណើរការនៃការបន្តថិរវេលានៃការឃុំខ្លួន ក្រោមវិធាន៦៣.៧ នៃវិធានផ្ទៃក្នុងគឺជាក់ស្តែងខុសពីដំណើរការនៃការឃុំខ្លួនពីលើកដំបូងអនុលោមតាមវិធាន៦៣.៣ នៃវិធានផ្ទៃក្នុង។ ដំណើរការការឃុំខ្លួនក្រោយនេះកើតមានឡើងនៅក្នុងពេល " សវនាការតទល់" មួយ ដែលពេលនោះសហព្រះរាជអាជ្ញាត្រូវបានធ្វើសវនាការផងដែរ ហើយដែលបន្ទុកក្នុងការស្វែងរកនិង និងក្នុងការធ្វើយុត្តិកម្មលើការឃុំខ្លួនគឺអាចអះអាងបានថាស្ថិតនៅលើ សហព្រះរាជអាជ្ញា ។

---

[31] សាលដីកាស្តីពីការបន្តថេរៈវេលានៃការឃុំខ្លួនបណ្តោះអាសន្ន, ទំព័រទី២ ។

១៩. ដើមបណ្តឹងឧទ្ធរណ៍បានចោទថា សាលដីកាស្តីពីការបន្តចិរវេលានៃការឃុំខ្លួននេះ គឺមានវិការៈខាងផ្នែកនីតិវិធី ដោយសារតែសហចៅក្រមស៊ើបអង្កេតមិនបានផ្តល់មូលដ្ឋានខាងអង្គហេតុ និងខាងអង្គច្បាប់ឱ្យបានគ្រប់គ្រាន់សម្រាប់ការធ្វើយុត្តិកម្មចំពោះការបន្តចិរវេលានោះទេ[32]។ សហព្រះរាជអាជ្ញា ធ្វើការកត់សំគាល់ថា ដើមបណ្តឹងឧទ្ធរណ៍មានសិទ្ធិជាស្វ័យប្រវត្តិក្នុងការប្តឹងឧទ្ធរណ៍ទៅកាន់អង្គជំនុំជម្រះនេះចំពោះសាលដីកាស្តីពីការបន្តចិរវេលានៃការឃុំខ្លួននេះរបស់សហចៅក្រមស៊ើបអង្កេតហើយអង្គជំនុំជម្រះនេះ អាច "ទទួលធ្វើការវិភាគរបស់ខ្លួនផ្ទាល់លើលក្ខខណ្ឌផ្សេងៗដូចដែលមានចែងនៅក្នុងវិធាន៦៣.៣"[33] ។ ដោយមិនគិតពីដើមបណ្តឹងឧទ្ធរណ៍បានខកខានក្នុងការបង្ហាញឱ្យឃើញ-ទាំងចំពោះសហចៅក្រមស៊ើបអង្កេត និងទាំងចំពោះអង្គជំនុំជម្រះនេះ-ថាមានការផ្លាស់ប្តូរខាងសម្ភារៈនៃកាលៈទេសៈ ដែលតម្រូវចាំបាច់ឱ្យធ្វើការពិនិត្យពិចារណាឡើងវិញលើការឃុំខ្លួន និង(២)ថា មូលហេតុដែលធ្វើយុត្តិកម្មលើការឃុំខ្លួនគឺមិនមានអត្ថិភាពតទៅទៀតទេ ។ សហព្រះរាជអាជ្ញា ជូនសេចក្តីសន្និដ្ឋានថា ការផ្លាស់ប្តូរខាងសម្ភារៈតែមួយគត់ដែលបានកើតមានឡើងចាប់តាំងពីពេលធ្វើការកំណត់សម្រេចលើការឃុំខ្លួនកាលពីលើកមុន គឺជាការបន្ថែមភស្តុតាងទៅក្នុងសំណុំរឿងដែលបញ្ជាក់អំពីការចោទប្រកាន់នានានៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ថា ឧក្រិដ្ឋកម្មមួយចំនួនក្នុងចំណោមឧក្រិដ្ឋកម្មដែលផ្តើមជាងគេបំផុតនៅក្នុងសតវត្សរ៍ទី២០ ត្រូវបានប្រព្រឹត្តដោយ *ខ្មែរក្រហម* និងថា ដើមបណ្តឹងឧទ្ធរណ៍គឺបានស្ថិតនៅលើកំពូលនៃប្រព័ន្ធការរំលោភបំពាននៅក្នុងទូទាំងប្រទេសនេះ។

## ខ. មូលហេតុដែលត្រូវបានរកឃើញយ៉ាងច្បាស់លាស់-វិធាន៦៣.៣.ក-មិនត្រូវបានតវ៉ាជំទាស់ទេ

២០. ដើមបណ្តឹងឧទ្ធរណ៍ ទទួលស្គាល់ការពិតអំពីអត្ថិភាពនៃមូលហេតុដែលត្រូវបានរកឃើញយ៉ាងច្បាស់ និងដែលគួរឱ្យជឿជាក់ថា គាត់ប្រហែលជាបានប្រព្រឹត្ត "ឧក្រិដ្ឋកម្មមួយចំនួនក្នុងចំណោមឧក្រិដ្ឋកម្ម" ដូចដែលបានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យសើបសួរប្រាកដ

[32] បណ្តឹងឧទ្ធរណ៍, កថាខណ្ឌទី២០ ។

[33] សេចក្តីសម្រេចបណ្តឹងឧទ្ធរណ៍ស្តីពីការឃុំខ្លួនរបស់ អៀង សារី, កថាខណ្ឌទី៦៨ ។

មែន[34] ។ គាត់បំភ្លឺថា "គាត់អាចនឹងត្រូវទទួលនូវការទទួលខុសត្រូវ-យ៉ាងម៉ឺងម៉ាត់តាមន័យនៅក្នុងវិធាន៦៣.៣.ក-តែចំពោះឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ណាដែលទាក់ទងទៅនឹងសកម្មភាពរបស់មន្ទីរស-២១តែប៉ុណ្ណោះ"[35] ។ អាស្រ័យហេតុនេះ គាត់មិនតវ៉ាជំទាស់ទៅនឹងការកំណត់សម្រេចអំពីមានមូលហេតុដែលត្រូវបានរកឃើញយ៉ាងច្បាស់នៅក្នុងសាលដីកាស្តីពីការបន្តថេរៈវេលានៃការឃុំខ្លួននោះទេ ។ វិធាន៦៣.៣.ក នៃវិធានផ្ទៃក្នុង មិនតម្រូវចំពោះតុលាការនេះថា ក្នុងការចេញដីកាបង្គាប់ឲ្យឃុំខ្លួនត្រូវតែមានមូលហេតុដែលត្រូវបានរកឃើញយ៉ាងច្បាស់ដែលគួរឲ្យជឿជាក់ថា ចុងចោទអាចបានប្រព្រឹត្តរាល់ឧក្រិដ្ឋកម្មទាំងអស់ដូចដែលបានលើកឡើងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ នោះទេ ។

២១. នៅក្នុងសាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនរបស់ខ្លួន អង្គបុរេជំនុំជម្រះ បានរកឃើញថា ឯកសារនៅក្នុងសំណុំរឿង "មុខជានឹងបំពេញបានគ្រប់គ្រាន់ចំពោះបុគ្គលដែលឯករាជ្យមិនលំអៀងអំពីថា [ដើមបណ្តឹងឧទ្ធរណ៍]អាចធ្លាប់បានទទួលខុសត្រូវ ឬ បានប្រព្រឹត្តឧក្រិដ្ឋកម្មទាំងឡាយដូចដែលបានលើកឡើងនៅក្នុងដីការសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនៅក្នុងដំណាក់កាលនេះនៃការស៊ើបសួរមែន"[36] ។ ចាប់តាំងពីការសម្រេចនោះមក ភស្តុតាងទាំងឡាយនៅក្នុងសំណុំរឿងដែលដាក់បន្ទុកទៅលើដើមបណ្តឹងឧទ្ធរណ៍ត្រូវបានកើនឡើងទាំងខាងបរិមាណផងនិងខាងស្ថានទម្ងន់ផង ។ យ៉ាងហោចណាស់ក៏ សហចៅក្រមស៊ើបអង្កេតបានចេញនូវដីកាចាត់ឲ្យស៊ើបសួរជំនួសចំនួនប្រាំបួន(៩)ដែរ នៅក្នុងសំណុំរឿងលេខ ០០២ (ឧទាហរណ៍ដូចជា ឯកសារលេខ D25, D40, D43, D82, D91, D93, D94 និង D104 ហើយសហចៅក្រមស៊ើបអង្កេត ឬអ្នកស៊ើបអង្កេតរបស់ខ្លួនបានធ្វើសម្ភាសន៍សាក្សីចំនួនជាងមួយរយនាក់ស្តីពីតួនាទីរបស់ជនទាំង៥រូបដែលត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿងនេះ ។

---

[34] បណ្តឹងឧទ្ធរណ៍, កថាខណ្ឌទី៦ ។

[35] បណ្តឹងឧទ្ធរណ៍, កថាខណ្ឌទី១៦ ។

[36] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួន របស់ នួន ជា, កថាខណ្ឌទី៥៨ ។

២២. ដើមបណ្តឹងឧទ្ធរណ៍ក៏បានទទួលស្គាល់ដោយមិនធ្វើការតវ៉ាជំទាស់ដែរថា ចម្លើយរបស់ ឌុច នៅចំពោះមុខតុលាការនេះ បាន "បង្ហាញឱ្យឃើញពីការជាប់ពាក់ព័ន្ធរបស់[គាត់] នៅក្នុងសកម្មភាពឧក្រិដ្ឋ" [37]។ ក្រៅពី ឌុច មានសាក្សីយ៉ាងច្រើនដែលបានបង្ហាញឱ្យឃើញថា គាត់មិនគ្រាន់តែបានជាប់ពាក់ព័ន្ធនៅក្នុងឧក្រិដ្ឋកម្មផ្សេងៗដែលត្រូវបានចោទប្រកាន់ថា បានប្រព្រឹត្តនៅមន្ទីរសន្តិសុខស-២១តែប៉ុណ្ណោះទេ ក៏ប៉ុន្តែបានជាប់ពាក់ព័ន្ធនៅក្នុងឧក្រិដ្ឋកម្មនៅទីកន្លែងក្រៅពីនេះទៀតផងដែរនៅក្នុងប្រទេសកម្ពុជា ក្នុងទូទាំងអម្លុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យទាំងមូល ។ ឧទាហរណ៍ដូចជា ភស្តុតាងនៅក្នុងសំណុំរឿង ដែលត្រូវបានដាក់បញ្ចូលបន្ថែមនៅក្រោយពីសាលដីការបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៨ បានគាំទ្រចំពោះ មូលហេតុដែលត្រូវបានរកឃើញយ៉ាងច្បាស់និងដែលគួរឱ្យជឿជាក់ថា ដើមបណ្តឹងឧទ្ធរណ៍ធ្លាប់ជាផ្នែកនៅក្នុងរចនាសម្ព័ន្ធនៃបញ្ជាការជាន់ខ្ពស់របស់*ខ្មែរក្រហម* ដែលទទួលខុសត្រូវចំពោះការបង្កើតនិងការអនុវត្តន៍នូវគោលនយោបាយដ៏ឧក្រិដ្ឋរបស់របបនោះ[38]។ មានសាក្សីមួយរូបធ្លាប់បានឃើញដើមបណ្តឹងឧទ្ធណ៍រូបនេះចូលរួមនៅក្នុងអង្គប្រជុំប្រចាំសប្តាហ៍ នៅឯមន្ទីរប-១ រួមជាមួយ អៀង សារី, ប៉ុល ពត, សុន សេន, ឌុច និងតាម៉ុក [39]។ មានសាក្សីម្នាក់ទៀតធ្លាប់បានឃើញដើមបណ្តឹងឧទ្ធរណ៍ព្រមជាមួយ ខៀវ សំផន, អៀង សារី, និង អៀង ធីរិទ្ធ នៅក្នុងពេលអង្គប្រជុំរៀនសូត្រផ្សេងៗនៅឯបូរីកីឡានិងនៅស្តាតអូឡាំពិក នៅក្នុងចន្លោះឆ្នាំ ១៩៧៦ និងឆ្នាំ១៩៧៧[40] ។ សាក្សីម្នាក់ទៀតបានឃើញដើមបណ្តឹងឧទ្ធរណ៍ជាមួយ សុន សេន នៅអង្គប្រជុំយោធាមួយនៅក្បែរវត្តភ្នំ[41] ។ សាក្សីផ្សេងៗទៀតបានឃើញការប្រជុំនានាស្រដៀងគ្នានេះរបស់ដើមបណ្តឹងឧទ្ធរណ៍ជាមួយនឹងមេដឹកនាំជាន់ខ្ពស់ដទៃៗទៀតរបស់*ខ្មែរ*

[37] បណ្តឹងឧទ្ធរណ៍, កថាខណ្ឌទី១៦ ។

[38] (បានលុបចេញ)

[39] (បានលុបចេញ)

[40] (បានលុបចេញ)

[41] (បានលុបចេញ)

*ក្រហម*[42] ។ មានសាក្សីមួយរូបបានធ្វើការកត់សំគាល់ថា ដើមបណ្ដឹងឧទ្ធរណ៍(ពេលនោះ) គឺជាអនុលេខា និងប៉ុល ពត ជាលេខារបស់បក្សកុម្មុយនីស្ដកម្ពុជា[43] ។

២៣. ភស្ដុតាងដែលការិយាល័យសហចៅក្រមស៊ើបអង្កេតប្រមូលបាន បានបញ្ជាក់ច្បាស់ថាការកើតមាននូវឧក្រិដ្ឋកម្មយ៉ាងច្រើនសន្ធឹកដូចដែលបានចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដែលត្រូវបានប្រព្រឹត្តក្នុងលក្ខណៈជាផ្នែកនៃសហកម្មឧក្រិដ្ឋកម្មរួម ដែលដើមបណ្ដឹងឧទ្ធរណ៍គឺជាអ្នកចូលរួមមួយរូបដ៏សំខាន់នៅក្នុងចំណោមនោះដែរ ។ ភស្ដុតាងបានបញ្ជាក់ច្បាស់ថា *ខ្មែរក្រហម*បានជម្លៀសប្រជាជនចេញពីភ្នំពេញ[44] ហើយក្រោយមកទៀតបានបង្ខំឱ្យប្រជាជនធ្វើពលកម្មដោយបង្ខំ[45] ។ ភស្ដុតាងក៏បានបង្ហាញឱ្យឃើញផងដែរថា ពួកគេបានប្រព្រឹត្តនូវការសម្លាប់មនុស្សជាទ្រង់ទ្រាយធំ[46] និងការធ្វើទារុណកម្ម[47]។ នៅក្រោមរបបខ្មែរក្រហម ប្រជាជនបានរស់នៅក្នុងស្ថានភាពដ៏អមនុស្សធម៌[48] ដោយពុំមានអាហារហូបចុកគ្រប់គ្រាន់[49] និងគ្មានពេទ្យព្យាបាល[50] ។ សាក្សីជាច្រើនបាននិយាយថាខ្មែរក្រហមបានបំផ្លួអរវត្តអារ៉ាមនានា[51] និងបានកំរិតព្រំដែនសេរីភាពក្នុងការដើរហើររបស់ប្រជាជនយ៉ាងធ្ងន់ធ្ងរ ដោយការបំបែកគ្រួសារនានាឱ្យនៅដាច់ពីគ្នា[52] ។

---

[42] (បានលុបចេញ)

[43] (បានលុបចេញ)

[44] (បានលុបចេញ)

[45] (បានលុបចេញ)

[46] (បានលុបចេញ)

[47] (បានលុបចេញ)

[48] (បានលុបចេញ)

[49] (បានលុបចេញ)

[50] (បានលុបចេញ)

[51] (បានលុបចេញ)

[52] (បានលុបចេញ)

00273359

C9/4/2



២៤. ពុំមានការរកឃើញនូវភស្តុតាងដោះបន្ទុកដែលសំខាន់ណាមួយ ដើម្បីនឹងធ្វើឲ្យខូចដល់ការកំណត់សម្រេចនេះអំពីអត្ថិភាពនៃមូលហេតុដែលត្រូវបានរកឃើញយ៉ាងច្បាស់និងដែលគួរឲ្យជឿជាក់នេះទេ ។ មកទល់ពេលនេះ ដើមបណ្តឹងឧទ្ធរណ៍មិនបានដាក់បញ្ចូលនូវឯកសារណាមួយដែលជាឯកសារដោះបន្ទុកឲ្យនៅតិចជាងនេះឲ្យបានក្រាស់ក្រៃលទៅក្នុងសំណុំរឿងដើម្បីនឹងជំរុញឲ្យធ្វើការពិនិត្យពិចារណាឡើងវិញទៅលើការកំណត់សម្រេចនេះទេ ។ ហេតុដូចនេះសហព្រះរាជអាជ្ញា សន្និដ្ឋានថា មូលហេតុដែលត្រូវបានរកឃើញយ៉ាងច្បាស់និងដែលគួរឲ្យជឿជាក់ នៅតែបន្តមានអត្ថិភាពតទៅទៀតថា ដើមបណ្តឹងឧទ្ធរណ៍អាចបានប្រព្រឹត្តអំពើឧក្រិដ្ឋផ្សេងៗដូចដែលបានបញ្ជាក់នៅក្នុងដីកាបញ្ជូនរឿងឲ្យស៊ើបសួរនោះមែន។

## គ. ការឃុំខ្លួនបណ្តោះអាសន្នស្ថិតនៅជាវិធានការមួយដ៏ចាំបាច់ដដែល

២៥. ដើមបណ្តឹងឧទ្ធរណ៍ មិនបានបង្ហាញអត្តសញ្ញាណនៃឯកសារណាមួយ អំពីការផ្លាស់ប្តូរផ្នែកសម្ភារៈនៃកាលៈទេសៈ ដើម្បីចង្អុលបង្ហាញពីលក្ខខណ្ឌផ្សេងៗដែលស្ថិតនៅក្រោមវិធាន ៦៣.៣.ខនៃវិធានផ្ទៃក្នុង ដែលថាមិនចាំបាច់បំពេញឲ្យបានគ្រប់គ្រាន់នូវលក្ខខណ្ឌតម្រូវសម្រាប់ការឃុំខ្លួនរបស់គាត់តទៅទៀតនោះទេ។ ទន្ទឹមនេះ គាត់ក៏មិនបានតវ៉ាជំទាស់ផងដែរចំពោះលក្ខខណ្ឌនៃការឃុំខ្លួនជាក់លាក់ណាមួយដោយផ្អែកលើហេតុផល ឬការវែកញែកហេតុផលជាក់ណាមួយដែរ ។ គាត់គ្រាន់តែបានធ្វើការពោលអះអាងដែលមិនមានការចង្អុលបង្ហាញភស្តុតាងជាក់លាក់ថា "ការិយាល័យសហចៅក្រមស៊ើបអង្កេត មានការខកខានមិនបានពន្យល់អំពីហានិភ័យ *ដែលបានបង្កើតឡើងជាទូទៅដែលត្រូវបានគេយកទៅប្រើប្រាស់ដើម្បីធ្វើយុត្តិកម្ម*ចំពោះការឃុំខ្លួនកាលពីលើកដំបូង[របស់គាត់] ដែលត្រូវបានទ្រទ្រង់ដោយភស្តុតាងជាក់ស្តែងតាមការតម្រូវនោះ តើធ្វើឡើងតាមរបៀបដូចម្តេច?"[53] ។

២៦. នៅក្នុងពេលដែលសហចៅក្រមស៊ើបអង្កេត បានផ្តល់នូវការវែកញែកហេតុផលដោយសង្ខេបសម្រាប់បំពេញឲ្យបានជាបន្តទៅទៀតអំពីលក្ខខណ្ឌនៃការឃុំខ្លួនហើយនោះ អង្គបុរេជំនុំជម្រះ

[53] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌទី១៧ ។ សេចក្តីសង្កត់ធ្ងន់ជាច្បាប់ដើម ។

អាច “ទទួលរ៉ាប់រងក្នុងការធ្វើការវិភាគផ្ទាល់របស់ខ្លួនលើលក្ខខណ្ឌផ្សេងៗដូចដែលមានចែងនៅក្នុងវិធាន ៦៣.៣ នៃវិធានផ្ទៃក្នុង”[54] ។ អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញាត្រូវតែបង្ហាញនៅក្នុងពេលឥឡូវនេះថា រាល់លក្ខខណ្ឌទាំងអស់នៃការឃុំខ្លួននៅក្រោមវិធាន ៦៣.៣.ខ បានបំពេញនិងបន្តបំពេញគ្រប់គ្រាន់តាមលក្ខណ្ឌសំរាប់ធ្វើយុត្តិកម្មចំពោះការបន្តថេរៈវេលានៃការឃុំខ្លួនរបស់ដើមបណ្តឹងឧទ្ធរណ៍ហើយ។

## *ការគាបសង្កត់ទៅលើសាក្សី-វិធាន៦៣.៣.ខ.១*
## *និង*
## *ការថែរក្សាភស្តុតាង*
## *ឬការពារកុំឲ្យបំផ្លាញភស្តុតាង-វិធាន៦៣.៣.ខ.២*

២៧. ដើមបណ្តឹងឧទ្ធរណ៍មិនបានប្រឆាំងជំទាស់ដោយជាក់លាក់ទៅនិងហេតុផលនៃការឃុំខ្លួនទាំងនោះទេ លើកលែងតែការបង្ហាញឲ្យឃើញអំពីការខ្វះការវែកញែកហេតុផលនៅក្នុងសាលដីកាស្តីពីការបន្តថេរៈវេលានៃការឃុំខ្លួនតែប៉ុណ្ណោះ[55] ។ ហេតុផលទាំងពីរនេះសម្រាប់ការឃុំខ្លួនបណ្តោះអាសន្នអាចត្រូវបានធ្វើវិភាគរួមគ្នាបានដោយសារហេតុផលទាំងនេះត្រូវបានគាំទ្រដោយទន្លីករណ៍តែមួយដដែល[56]។ នៅក្នុងការវិភាគនេះ ចម្លើយដែលសាក្សីបានផ្តល់អាចត្រូវបានចាត់ទុកថាជា “ភស្តុតាង” ដែលស្ថិតនៅក្នុងរង្វង់អត្ថន័យនៃវិធាន៦៣.៣.ខ.២[57] ។

២៨. បច្ចុប្បន្ននេះ សំណុំរឿងទាំងមូលមានជាស្រេចហើយទុកសម្រាប់ឲ្យដើមបណ្តឹងឧទ្ធរណ៍ពិនិត្យមើល ដែលរួមមានទាំងឈ្មោះជនរងគ្រោះ, ដើមបណ្តឹងរដ្ឋប្បវេណី, និងសាក្សីដ៏មានសក្តានុពលនានា[58] ។ សាក្សីដែលនៅរស់រានមានជីវិតគឺមានតិចតួចតែប៉ុណ្ណោះដែលអាចផ្តល់

---

[54] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនរបស់ **អៀង សារី**, កថាខណ្ឌទី៦៨ ។

[55] បណ្តឹងឧទ្ធរណ៍, កថាខណ្ឌទី១៧ ។

[56] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនរបស់ **អៀង សារី**, កថាខណ្ឌទី៩៥ ។

[57] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនរបស់ **អៀង សារី**, កថាខណ្ឌទី៩៥ ។

[58] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនរបស់ **អៀង សារី**, កថាខណ្ឌទី៩៦ ។

សក្ខីកម្មអំពីការចូលរួមរបស់ដើមបណ្ដឹងឧទ្ធរណ៍នៅក្នុងឧក្រិដ្ឋកម្មដែលបានចោទប្រកាន់[59]។ សាក្សីមួយចំនួនក្នុងចំណោមសាក្សីទាំងនោះ សហចៅក្រមស៊ើបអង្កេតមិនទាន់បានធ្វើសម្ភាសន៍ពួកគេនៅឡើយ [60]។ សូម្បីតែសាក្សីទាំងនោះត្រូវបានស្ដាប់ចម្លើយនិងបានផ្ដល់ភស្តុតាងរួចហើយក្ដី ក៏ពួកគេនៅតែមានឱកាសអាចត្រូវបានស្ដាប់ចម្លើយនៅពេលក្រោយៗទៀតនៅឡើយ ក្នុងអម្លុងពេលស៊ើបសួរ ឬសវនាការដែលត្រូវធ្វើជាបន្ដៗទៅទៀត[61] ។

២៩. ក្នុងពេលកន្លងទៅ ដើមបណ្ដឹងឧទ្ធរណ៍បានខិតខំធ្វើការគម្រាមមកំហែងសាក្សីនានាឬស្វែងរកបំផ្លាញចោលនូវភស្តុតាងនានា[62] ។ អង្គបុរេជំនុំជម្រះបានកត់សំគាល់ថា មានភវនីយភាពដែលថា គាត់ទំនងជានឹងប្រព្រឹត្តបែបនេះមែន នៅក្នុងពេលអនាគត[63] ។ ដោយយល់ឃើញថាមានសាក្សីដ៏មានសក្ដានុពលនានាបានសំដែងការភ័យខ្លាចក្នុងការចូលទៅផ្ដល់សក្សីកម្មនៅចំពោះមុខតុលាការនេះ បើសិនជាទំនោរបែបនេះរបស់ដើមបណ្ដឹងឧទ្ធរណ៍ត្រូវបានលេចឮទៅដល់ជនរងគ្រោះនិងសាក្សីនានានោះ គឺវាអាចមានផលវិបាកបញ្ច្រាសមកវិញដែលធ្វើឲ្យប៉ះពាល់ដល់ឆន្ទៈរបស់ពួកគាត់ដែលចង់ទៅផ្ដល់សក្ខីកម្មនៅចំពោះមុខតុលាការនេះ ជាពិសេសគឺប្រសិនជាជននេះត្រូវបានគេដោះលែង[64] ។ ដើមបណ្ដឹងឧទ្ធរណ៍បាន "យល់ព្រមទទួលស្គាល់ការពិត " រួចហើយ អំពីថាអាចនឹងមានមូលហេតុដែលត្រូវបានរកឃើញយ៉ាងច្បាស់និងដែលគួរឲ្យជឿជាក់ថាគាត់អាចបានប្រព្រឹត្តអំពើឧក្រិដ្ឋផ្សេងៗនៅឯមន្ទីរសន្តិសុខស-២១មែន[65] ។ មានសាក្សីដែលនៅរួចរស់ជីវិតអំពីឧក្រិដ្ឋកម្មផ្សេងៗនៅក្នុងមន្ទីរសន្តិសុខនេះតែតិតួចប៉ុណ្ណោះ។

៣០. ដើមបណ្ដឹងឧទ្ធរណ៍បានទទួលស្គាល់ ហើយសាក្សីនានាបានបញ្ជាក់ច្បាស់ថា គាត់បានកាន់

[59] សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនរបស់ **អៀង សារី**, កថាខណ្ឌទី៨៦ ។

[60] សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនរបស់ **អៀង សារី**, កថាខណ្ឌទី៨៦ ។

[61] សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនរបស់ **នួន ជា**, កថាខណ្ឌទី៦០ ។

[62] សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនរបស់ **នួន ជា**, កថាខណ្ឌទី៦១-២ ។

[63] សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនរបស់ **នួន ជា**, កថាខណ្ឌទី៦២ ។

[64] សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនរបស់ **នួន ជា**, កថាខណ្ឌទី៦៣ ។

[65] បណ្ដឹងឧទ្ធរណ៍, កថាខណ្ឌទី៦ ។ សេចក្ដីសង្កត់ធ្ងន់ជាច្បាប់ដើម ។

កាប់មុខតំណែងជាន់ខ្ពស់មួយចំនួននៅក្នុងចលនា*ខ្មែរក្រហម* ។ មានឥទ្ធិពលខ្លះចាំបាច់ត្រូវផ្សារភ្ជាប់គ្នាទៅនឹងមុខតំណែងជាន់ខ្ពស់ទាំងនោះ ។ គឺជាឥទ្ធិពលដែលអាចត្រូវបានយកមកប្រើ សូម្បីតែក្នុងពេលបច្ចុប្បន្ននេះក្តី[66] ។ ហេតុដូចនេះ ការឃុំខ្លួនដើមបណ្តឹងឧទ្ធរណ៍ គឺជាការចាំបាច់ដើម្បីទប់ស្កាត់កុំឱ្យជននេះប្រើឥទ្ធិពលដើម្បីធ្វើការគាបសង្កត់ចំពោះសាក្សីនានា ឬកុំឱ្យបំផ្លាញភស្តុតាង[67] ។

## *ការធានាអំពីវត្តមានរបស់ជនត្រូវចោទនៅក្នុងដំណើរការនីតិវិធី*
## *វិធាន ៦៣.៣.ខ(៣)*

៣១. នៅក្នុងបណ្តឹងឧទ្ធរណ៍របស់ខ្លួន ភាគីប្តឹងឧទ្ធរណ៍មិនបានជំទាស់ឱ្យបានជាក់លាក់ទៅនឹងទឡ្ហីករណ៍នេះទេ[68] ។ តាមសភាពនៃស្ថានទម្ងន់នៃបទចោទទាំងឡាយដែលបានចោទប្រកាន់លើរូបគាត់ ភាគីប្តឹងឧទ្ធរណ៍ទំនងជាត្រូវបានកាត់ទោសដាក់ពន្ធនាគារអស់មួយជីវិត[69] ។ តុលាការព្រហ្មទណ្ឌអន្តរជាតិនានា ដែលមានលក្ខណៈស្រដៀងគ្នាទៅនឹងអង្គជំនុំជម្រះនេះ បានសម្រេចថា ស្ថានទម្ងន់នៃបទចោទទាំងឡាយដែលបានចោទប្រកាន់ រួមផ្សំជាមួយនឹងកត្តាដទៃទៀត អាចជាកត្តាពាក់ព័ន្ធមួយដើម្បីបដិសេធការដោះលែង[70] ។ ការប្រកាសទោស [ឱ្យជាប់ពន្ធនាគារ] ដែលមានរយៈពេលយូរ គឺជាគ្រឿងលើកទឹកចិត្តមួយ នាំឱ្យមានការមិនមកបង្ហាញខ្លួននៅចំពោះមុខតុលាការ[71] ។

---

66 សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនរបស់ **នួន ជា**, កថាខណ្ឌទី៦២ ។

67 សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនរបស់ **នួន ជា**, កថាខណ្ឌទី៦៤ ។

68 បណ្តឹងឧទ្ធរណ៍, កថាខណ្ឌទី ១៧ ។

69 សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួន, កថាខណ្ឌទី ៦៥ ។

70 *រដ្ឋអាជ្ញា ទល់នឹង Gotovina, Cermak និង Markac,* សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ Ante Govina ជំទាស់នឹងការបដិសេធលើការដោះលែងបណ្តោះអាសន្ន, សំណុំរឿងលេខ IT-06-90-AR65.1, អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ICTY, ចុះថ្ងៃទី១៧ មករា ២០០៨, កថាខណ្ឌទី ១៥ (C40.1, ឧបសម្ព័ន្ធដែលមានចំណងជើងថា "តារាងប្រភពច្បាប់", ឯកសារភ្ជាប់លេខ ៣០, ERN 00228948-56) [*បន្ទាប់ពីនេះទៅហៅថា៖* សាលដីកាសម្រេចលើករណីរបស់ Gotovina] ។

71 *ស្ថានភាពនៅសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ ក្នុងករណីរវាង រដ្ឋអាជ្ញា ទល់នឹង Thomas Lubanga Dyilo,* សេចក្តីសម្រេចលើពាក្យសុំឱ្យមានការដោះលែង Thomas Lubanga Dyilo ជាបណ្តោះអាសន្ន, សំណុំរឿងលេខ 01/04-01/06, ចៅក្រមតែម្នាក់គត់របស់តុលាការ ICC, ចុះថ្ងៃទី១៨ តុលា ២០០៦, ទំព័រទី ៥-៦ (C11/11, Authority C 13, ERN 00153776) ។

C 9/4/2



៣២. អង្គបុរេជំនុំជម្រះ បានកត់សម្គាល់ថា លំនៅដ្ឋានរបស់ភាគីប្តឹងឧទ្ធរណ៍នៅទីក្រុងប៉ៃលិន គឺស្ថិតនៅជិតបង្កើយនឹងព្រំដែនកម្ពុជា-ថៃ ហើយហានិភ័យនៃការរត់គេចខ្លួនគឺមាននៅជាប់ជាមួយនោះ[72] ។ ហានិភ័យនេះ គឺកាន់តែធ្ងន់ឡើងដោយសារទីតាំងនៃលំនៅដ្ឋានរបស់គាត់ស្ថិតក្នុង "តំបន់ដែលគេស្គាល់ថាជា [អតីត] តំបន់ដែលមានការគាំទ្រ [ខ្លាំងក្លា] របស់ *ខ្មែរក្រហម*"[73] ។ អង្គបុរេជំនុំជម្រះ បានរកឃើញថា វាទំនងជាអ្នកដែលធ្លាប់ទាក់ទងគ្នាជាមួយនឹងភាគីប្តឹងឧទ្ធរណ៍នៅតំបន់នោះ "មានទំនាក់ទំនងល្អ" ហើយថាពួកនោះអាចនឹងជួយជ្រោមជ្រែងឲ្យមានលទ្ធភាពក្នុងការរត់គេចខ្លួន[74] ។

៣៣. អង្គហេតុទាំងនេះបង្ហាញថា ការដោះលែងភាគីប្តឹងឧទ្ធរណ៍ មុខជានឹងកាត់បន្ថយនូវភាពទំនងជាចូលខ្លួនរបស់គាត់នៅចំពោះមុខអង្គជំនុំជម្រះនេះជាមិនខាន ។ ហេតុដូច្នេះ ការបន្តឃុំខ្លួនរបស់គាត់ គឺជាវិធានការចាំបាច់ ។

## *ការការពារសន្តិសុខឲ្យជនដែលត្រូវចោទ*
## *វិធាន ៦៣.៣.ខ(៤)*

៣៤. នៅក្នុងបណ្តឹងឧទ្ធរណ៍របស់ខ្លួន ភាគីប្តឹងឧទ្ធរណ៍មិនបានជំទាស់ឲ្យបានជាក់លាក់ទៅនឹងទឡ្ហីករណ៍នេះទេ[75] ។ ដូចជាអ្នកដឹកនាំជាន់ខ្ពស់ *ខ្មែរក្រហម* ដទៃទៀត ដែលអង្គជំនុំជម្រះនេះបានឃុំខ្លួនដែរ ភាគីប្តឹងឧទ្ធរណ៍ គឺជាមនុស្សដែលគេបានស្គាល់ជាទូទៅនៅប្រទេសកម្ពុជា[76] ។ អង្គបុរេជំនុំជម្រះ បានកត់សម្គាល់ឃើញថា ការគម្រាមកំហែងដែលបានធ្វើឡើងប្រឆាំងនឹងជនត្រូវចោទឈ្មោះ ឌុច ក្នុងអំឡុងពេលសវនាការជាសាធារណៈជាលើកដំបូងរបស់

---

[72] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួន នួន ជា, កថាខណ្ឌទី ៦៧ ។

[73] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួន នួន ជា, កថាខណ្ឌទី ៦៨ ។

[74] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួន នួន ជា, កថាខណ្ឌទី ៦៨ ។

[75] បណ្តឹងឧទ្ធរណ៍, កថាខណ្ឌទី ១៧ ។

[76] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួន អៀង សារី, កថាខណ្ឌទី ១០៧ ។ ការសម្រេចនេះ មាននៅក្នុងបរិបទនៃសហជនត្រូវចោទ អៀង សារី ដែលជាការអនុវត្តន៍បានដូចគ្នានៅក្នុងបរិបទនៃភាគីប្តឹងឧទ្ធរណ៍នេះ ។
ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា ស្តីពីការសុំពន្យារពេលការឃុំខ្លួនបណ្តោះអាសន្ន

អង្គជំនុំជម្រះនេះ ហើយបានប្រមើលមើលឃើញថា ការប្រទូសរ៉ាយបែបដូចនេះក៏អាចនឹងត្រូវបានបញ្ចេញប្រឆាំងនឹងភាគីប្ដឹងឧទ្ធរណ៍បានផងដែរ ជាពិសេស គឺបន្ទាប់ពីមានភស្តុតាងគ្រប់គ្រាន់ដែលត្រូវបានគេកត់ត្រាទុករួចហើយនោះ បង្ហាញថាគាត់មានការជាប់ពាក់ព័ន្ធនៅក្នុងឧក្រិដ្ឋកម្មទាំងនោះ[77] ។ ជាការផ្ទុយទៅនឹងសារណារបស់ភាគីប្ដឹងឧទ្ធរណ៍ ការកន្លងហួសទៅនៃពេលវេលា គឺមិនបានកាត់បន្ថយនូវភាពពាក់ព័ន្ធនៃការគម្រាមកំហែងទាំងនេះទេ ។ តាមពិតទៅ ភាពពាក់ព័ន្ធនៃការគម្រាមកំហែងទាំងនេះ នឹងមានការកើនឡើងដោយសារតែឥឡូវនេះ សាធារណជនកំពុងចាប់ផ្ដើមមានជំនឿថា មានទីបញ្ចប់នៃនិទណ្ឌភាពសម្រាប់ពួកមេដឹកនាំ *ខ្មែរក្រហម* ។

៣៥. អង្គហេតុទាំងនេះបង្ហាញថា ការដោះលែងភាគីប្ដឹងឧទ្ធរណ៍ នឹងពិតជាមានគ្រោះថ្នាក់ ដល់សន្តិសុខផ្ទាល់ខ្លួនរបស់គាត់ជាមិនខាន ។ ហេតុដូច្នេះ ការបន្តឃុំខ្លួនរបស់គាត់គឺជាវិធានការចាំបាច់ ។

***ការរក្សាសណ្ដាប់ធ្នាប់សាធារណៈ:***
***វិធាន ៦៣.៣.ខ(៥)***

៣៦. នៅក្នុងបណ្ដឹងឧទ្ធរណ៍របស់ខ្លួន ភាគីប្ដឹងឧទ្ធរណ៍មិនបានជំទាស់ឲ្យបានជាក់លាក់ទៅនឹងទឡ្ហីករណ៍នេះទេ[78] ។ ការកន្លងហួសទៅនៃពេលវេលា មិនបានកាត់បន្ថយនូវផលប៉ះពាល់នៃរបបកម្ពុជាប្រជាធិបតេយ្យទៅលើសង្គមកម្ពុជាទេ[79] ។ សមាមាត្រនៃប្រជាជនកម្ពុជាមួយចំនួនដែលធ្លាប់បានរស់នៅក្នុងរយៈកាលនោះ នៅតែមានការឈឺចាប់ដែលបណ្ដាលមកពីភាពតានតឹងក្នុងអារម្មណ៍ក្រោយពេលមានការប៉ះទង្គិចធ្ងន់ធ្ងរនៅឡើយទេ (Post Traumatic Stress Disorder - PTSD)[80] ។ អ្នកឯកទេសបានជជែកថា ការចាប់ផ្ដើមសកម្មភាពតាម

---

[77] សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួន នួន ជា, កថាខណ្ឌទី ៧១ ។

[78] បណ្ដឹងឧទ្ធរណ៍, កថាខណ្ឌទី ១៧ ។

[79] សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួន នួន ជា, កថាខណ្ឌទី ៧៧ ។

[80] សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួន នួន ជា, កថាខណ្ឌទី ៧៧ ។

ផ្លូវតុលាការរបស់អង្គជំនុំជម្រះនេះ“អាចធ្វើឱ្យមានហានិភ័យថ្មីទៀតដល់សង្គមកម្ពុជា” ហើយវាអាច“នាំឱ្យមានការកើតឡើងវិញនៃភាពភ័យខ្លាចនិងផលវិបាកជាអវិជ្ជមានក្នុងសង្គម”[81] ។

៣៧. អង្គបុរេជំនុំជម្រះ បានកត់សម្គាល់ឃើញថា សវនាការទាំងឡាយនៅចំពោះមុខអង្គជំនុំជម្រះនេះ បានធ្វើឱ្យមានការចាប់អារម្មណ៍មួយចំនួនធំពីសំណាក់ប្រជាជនកម្ពុជា និងបណ្តាញផ្សព្វផ្សាយព័ត៌មាន ក៏ដូចជាសហគមន៍អន្តរជាតិផងដែរ[82] ។ ការចាប់អារម្មណ៍នេះ បង្ហាញថាដំណើរការនីតិវិធីទាំងនេះ សូម្បីតែនៅដំណាក់ការជំនុំជម្រះមុនអង្គសេចក្តីក៏ដោយ ក៏នៅតែជាការខ្វល់ខ្វាយដ៏ធំមួយរបស់ប្រជាជនកម្ពុជា និងសហគមន៍អន្តរជាតិ[83] ។

៣៨. បើទុកណាជាគេតម្រូវឱ្យមានភស្តុតាងជាក់លាក់ ដើម្បីគាំទ្រដល់ហានិភ័យជាក់ស្តែងមួយដែលថាសណ្តាប់ធ្នាប់សាធារណៈ អាចនឹងត្រូវបានគេរំខាន បើសិនជាចុងចម្លើយណាម្នាក់ត្រូវបានគេដោះលែងក៏ដោយក៏ ការប៉ាន់ប្រមាណនេះចាំបាច់ត្រូវមានការពាក់ព័ន្ធទៅនឹងវិធាននៃការព្យាករណ៍ ជាពិសេសនៅក្នុងបរិបទស្តីពីបទឧក្រិដ្ឋនានាដែលមាននៅក្នុងយុត្តាធិការនៃអង្គជំនុំជម្រះនេះ ។ ការគម្រាមកំហែងចំពោះសន្តិសុខដែលគេបានមើលឃើញ គឺមិនមែនជា [ការគម្រាមកំហែង] ដែលមិនពិតនោះទេ (The perceived threat is not illusory)[84] ។ នៅក្នុងការសម្រេចយ៉ាងដូច្នេះ អង្គបុរេជំនុំជម្រះ បានយកសេចក្តីកត់សម្គាល់តាមផ្លូវតុលាការនៃ “បញ្ហាអសន្តិសុខដែលកើតមានឡើងជារៀងរាល់ថ្ងៃ ឬ តាមរយៈបទឧក្រិដ្ឋហិង្សាផ្សេងៗទៀត”[85] ។ អង្គហេតុទាំងនេះបង្ហាញថា ការដោះលែងភាគីប្តឹងឧទ្ធរណ៍ នឹងពិតជាមានការរំខានដល់សណ្តាប់ធ្នាប់សាធារណៈជាមិនខាន ។ ហេតុដូច្នេះ ការបន្តឃុំខ្លួនរបស់គាត់គឺជាវិធានការចាំបាច់ ។

---

[81] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួន នួន ជា, កថាខណ្ឌទី ៧៧ ។

[82] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួន នួន ជា, កថាខណ្ឌទី ៧៩ ។

[83] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួន នួន ជា, កថាខណ្ឌទី ៧៩ ។

[84] *ករណីរបស់ អៀង ធីរិទ្ធ,* សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នលើឈ្មោះ អៀង ធីរិទ្ធ, ចុះថ្ងៃទី ០៩ កក្កដា ២០០៨, C20/I/27, ERN 00201633-49, កថាខណ្ឌទី ៦៥ និង ៦៩ ។

[85] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួន នួន ជា, កថាខណ្ឌទី ៨០ ។

## គ. លក្ខខណ្ឌទាំងនោះមិនធានាឱ្យមាន ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការទេ

៣៩. ភាគីប្តឹងឧទ្ធរណ៍ អះអាងថា ទាំងសហចៅក្រមស៊ើបអង្កេត ទាំងអង្គបុរេជំនុំជម្រះ មិនបានពិចារណាអំពី "ការកំណត់ឱ្យមានវិធានការធូរស្រាលមួយ" ក្នុងលក្ខណៈជាការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ជាជំនួសការឃុំខ្លួនទេ ។ ក្នុងការស្វែងរក [ទីកន្លែងដែល] នៅជិត [ដើម្បីឱ្យទទួលបាននូវ] សេវាពេទ្យជាបន្ទាន់ គាត់មានប្រាថ្នាចង់ឱ្យគេ "ឃុំខ្លួននៅក្នុងផ្ទះ" ដែលស្ថិតនៅឯមន្ទីរពេទ្យណាមួយដែលត្រូវបានយល់ព្រម នៅកណ្តាលទីក្រុងភ្នំពេញ[86] ។

៤០. នៅក្នុងសាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួន អង្គបុរេជំនុំជម្រះ បានកត់សម្គាល់ថា ក្នុងករណីរបស់ភាគីប្តឹងឧទ្ធរណ៍ ទឡ្ហីករណ៍ទាំងប្រាំដែលត្រូវមានយុត្តិកម្មនៅក្រោមវិធាន ៦៣.៣.ក គឺត្រូវទៅតាម [វិធាន] នោះហើយ បើទោះបីជាមានតែទឡ្ហីករណ៍ណាមួយក្នុងចំណោមទឡ្ហីករណ៍ទាំងនោះមានលក្ខណៈគ្រប់គ្រាន់ក្នុងការធ្វើយុត្តិកម្មលើការឃុំខ្លួនក៏ដោយ[87] ។ អង្គបុរេជំនុំជម្រះ បានរកឃើញថា ការឃុំខ្លួនគឺជាការចាំបាច់ដើម្បីធានាសន្តិសុខរបស់សាក្សីនានា និងភាគីប្តឹងឧទ្ធរណ៍, ដើម្បីថែរក្សាភស្តុតាង, ដើម្បីធានាអំពីវត្តមានរបស់ភាគីប្តឹងឧទ្ធរណ៍នៅក្នុងដំណើរការនីតិវិធី និងដើម្បីរក្សាសណ្តាប់ធ្នាប់សាធារណៈ[88] ។ អង្គបុរេជំនុំជម្រះ បានសម្រេចថា មិនមានការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការណាមួយដែលហ្មត់ចត់គ្រប់គ្រាន់ល្មមនឹងដោះស្រាយនូវកង្វល់ទាំងនេះឡើយ[89] ។

---

[86] បណ្តឹងឧទ្ធរណ៍, កថាខណ្ឌទី ២១ ។

[87] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួន នួន ជា, កថាខណ្ឌទី ៨៣ ។

[88] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួន នួន ជា, កថាខណ្ឌទី ៨៣ ។

[89] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួន នួន ជា, កថាខណ្ឌទី ៨៣ ។

C9/4/2



៤១. ដូចដែលបានថ្លែងខាងលើ វិធានផ្ទៃក្នុងមិនបានចែងឱ្យបានច្បាស់លាស់អំពីទម្រង់ផ្សេងទៀត ដែលជាជម្រើសនៃការឃុំខ្លួនទេ[90] ។ នៅក្នុងករណីរបស់ អៀង សារី ដែលបានស្វែងរកនូវដំណោះស្រាយស្រដៀងគ្នា អង្គបុរេជំនុំជម្រះបានរកឃើញថា សូម្បីតែចុងចោទម្នាក់ដែលត្រូវបានដាក់ឱ្យនៅក្រោម "ការឃុំខ្លួននៅមន្ទីរពេទ្យ" ក៏នៅតែអាចមានហានិភ័យខ្ពស់ចំពោះសុវត្ថិភាពផ្ទាល់ខ្លួនដែរ[91] ។ គាត់មុខជានឹងត្រូវបានតម្រូវឱ្យមកអង្គុយនៅកៅអីរបស់ អង្គជំនុំជម្រះនេះជាច្រើនលើកច្រើនសារ ហើយមានការពិបាកណាស់ក្នុងការធានាអំពី សុវត្ថិភាពរបស់គាត់ នៅពេលដឹកគាត់មកពីមន្ទីរពេទ្យ ឬពីផ្ទះរបស់គាត់ទៅកាន់ អង្គជំនុំជម្រះនេះ ដើម្បីចូលរួមនៅក្នុងសវនាការសាធារណៈទាំងឡាយដែលបានគ្រោងទុក[92] ។ អង្គជំនុំជម្រះ បានរកឃើញថាគេបាន "បំពាក់គ្រឿងឧបករណ៍យ៉ាងត្រឹមត្រូវដើម្បីផ្តល់នូវជំនួយផ្នែកពេទ្យនៅពេលមានតម្រូវការចាំបាច់" សម្រាប់មន្ទីរឃុំឃាំងរបស់ អ.វ.ត.ក[93] ។

៤២. នៅថ្ងៃទី០៩ ខែតុលា ឆ្នាំ២០០៨ ក្នុងអំឡុងពេលសវនាការមួយ នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ស្តីពីលក្ខខណ្ឌនៃការឃុំខ្លួនរបស់គាត់ ភាគីប្តឹងឧទ្ធរណ៍បានកត់សម្គាល់ថា "លក្ខខណ្ឌនៃការឃុំខ្លួនខ្ញុំមានលក្ខណៈសមរម្យ: ខ្ញុំទទួលយកបាន"[94] ។ អង្គជំនុំជម្រះ ក៏បានរកឃើញផងដែរថា សហចៅក្រមស៊ើបអង្កេត បានចាត់តាំងគ្រូពេទ្យជំនាញផ្នែកបេះដូងចំនួនបួននាក់ (ជាជនជាតិបារាំង, ថៃ និង កម្ពុជា) ដើម្បីធ្វើការស្ទាបស្ទង់ស្ថានភាពសុខភាពរបស់ភាគីប្តឹងឧទ្ធរណ៍[95] ។ នៅពេលថ្មីៗនេះ សហចៅក្រមស៊ើបអង្កេត បានចាត់តាំងគ្រូពេទ្យជំនាញផ្នែកបេះដូងចំនួនពីរនាក់ ដើម្បីធ្វើការស្ទាបស្ទង់បន្ថែមទៀតអំពីស្ថានភាពសុខភាព

---

[90] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួន អៀង សារី, កថាខណ្ឌទី ១១៩ ។

[91] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួន អៀង សារី, កថាខណ្ឌទី ១២២ ។

[92] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួន អៀង សារី, កថាខណ្ឌទី ១២២ ។

[93] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួន អៀង សារី, កថាខណ្ឌទី ១២៣ ។

[94] *ករណីរបស់ នួន ជា,* កំណត់ហេតុនៃការសាកសួរទាក់ទងនឹងលក្ខខណ្ឌនៃការឃុំខ្លួន, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, ERN 00229527-00229529, C39, ចុះថ្ងៃទី០៩ តុលា ២០០៨, ទំព័រទី ២ ។

[95] *ករណីរបស់ នួន ជា,* សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ចំពោះការចាត់តាំងអ្នកជំនាញ, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អបជ-០៧), ERN 00233587-00233598, D54/V/5, ចុះថ្ងៃទី២២ តុលា ២០០៨, កថាខណ្ឌទី ៣៦, ៣៩ ។

របស់ភាគីប្តឹងឧទ្ធរណ៍[96] ។ រហូតមកទល់ពេលនេះ អ្នកជំនាញការដែលបានចាត់តាំង បានធ្វើការសន្និដ្ឋានថានៅពេលនេះ ដោយសារតែវ័យជរារបស់ភាគីប្តឹងឧទ្ធរណ៍តម្រូវជាចាំបាច់ឱ្យមានការត្រួតពិនិត្យមើលជាបន្តបន្ទាប់នោះ សុខភាពទូទៅ និងការចងចាំរបស់គាត់ គឺមានលក្ខណៈសមស្របទៅនឹងអាយុ និងលក្ខណៈរបស់គាត់[97] ។ គ្រូពេទ្យជំនាញផ្នែកបេះដូង ជាជនជាតិបារាំង បានធ្វើការសន្និដ្ឋានថា៖ "វាជាការលំបាក ក្នុងការប្រាប់ឱ្យដឹងជាមុនពីអនាគត ប៉ុន្តែបើតាមការពិនិត្យយ៉ាងហ្មត់ចត់នេះ ឃើញថា [ភាគីប្តឹងឧទ្ធរណ៍] ទទួលបាននូវស្ថេរភាពខាងរោគសាស្ត្រយ៉ាងពិតប្រាកដ ដែលធ្វើឱ្យគាត់គេចផុតពីការឈឺចាប់ ។ [...] គេត្រូវចងចាំក្នុងចិត្តថា អ្នកជម្ងឺរូបនេះគឺជាមនុស្សចាស់ ដែលតម្រូវឱ្យធ្វើបច្ចុប្បន្នភាពម្តងម្កាលនៅក្នុងរយៈពេល*ពីរ-បីខែម្តង*"[98] ។

៤៣. ក្រៅពីការយោងទៅដល់រយៈចម្ងាយពី អ.វ.ត.ក ទៅ "កណ្តាលទីក្រុងភ្នំពេញ" ភាគីប្តឹងឧទ្ធរណ៍ មិនបានកំណត់អត្តសញ្ញាណអំពីទឡ្ហីករណ៍ជាក់លាក់ណាមួយ ដើម្បីធ្វើយុត្តិកម្មទៅលើការសម្រាកពេទ្យជាអចិន្ត្រៃយ៍របស់ខ្លួន "នៅឯមន្ទីរពេទ្យណាមួយដែលត្រូវបានយល់ព្រម"[99] ទេ ។ ការសម្រាកពេទ្យ ឬ ការសង្គ្រោះបន្ទាន់ផ្នែកពេទ្យ មិនអាចរកភស្តុតាងបានតាមការកំណត់តាមផ្លូវច្បាប់ទេ ។ ការសម្រាកពេទ្យ ឬ ការសង្គ្រោះបន្ទាន់ផ្នែកពេទ្យ ជាការសម្រេចពិសេសផ្នែកពេទ្យ ដែលជាភារកិច្ចរបស់គ្រូពេទ្យ និងអ្នកជំនាញ[100] ។ សហព្រះរាជ

---

[96] *ករណីរបស់ នួន ជា,* ដីកាចាត់តាំងអ្នកជំនាញ, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, ERN 00226126-00226128, B14, ចុះថ្ងៃទី០៦ តុលា ២០០៨, ទំព័រទី ២ ។

[97] *ករណីរបស់ នួន ជា,* ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា ស្តីពីការសុំតែងតាំងអ្នកជំនាញការពិនិត្យលើភាពសមស្របរបស់គាត់ដើម្បីឡើងសវនាការ, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អបជ-០៧), ERN 00196845-00196854, D54/V/2, ចុះថ្ងៃទី១៧ មិថុនា ២០០៨, កថាខណ្ឌទី ៨ ។

[98] *ករណីរបស់ នួន ជា,* ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា ស្តីពីការសុំតែងតាំងអ្នកជំនាញការពិនិត្យលើភាពសមស្របរបស់គាត់ដើម្បីឡើងសវនាការ, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អបជ-០៧), ERN 00196845-00196854, D54/V/2, ចុះថ្ងៃទី១៧ មិថុនា ២០០៨, កថាខណ្ឌទី ១០, សង្កត់ន័យបន្ថែមដោយ *អក្សរទ្រេត* ។

[99] បណ្តឹងឧទ្ធរណ៍, កថាខណ្ឌទី ២១ ។

[100] *ករណីរបស់ នួន ជា,* កំណត់ហេតុនៃការសាកសួរទាក់ទងនឹងលក្ខខណ្ឌនៃការឃុំខ្លួន, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, ERN 00229527-00229529, C39, ចុះថ្ងៃទី០៩ តុលា ២០០៨, ទំព័រទី ២ ។

ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា ស្តីពីការសុំពន្យារពេលការឃុំខ្លួនបណ្តោះអាសន្ន

C 9/4/2

សំណុំរឿងលេខៈ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ១៣)

អាជ្ញា កត់សម្គាល់ជាច្រើនដងឃើញថា នៅពេលចុងចម្លើយនានាដែលត្រូវបានអង្គជំនុំជម្រះនេះបានឃុំខ្លួន ត្រូវការពិនិត្យផ្នែកពេទ្យ ពួកនោះត្រូវបានគេបញ្ជូនទៅកាន់មន្ទីរពេទ្យសមស្របដែលនៅខាងក្រៅ ។ ជាការពិត អ្នកខ្លះត្រូវបានគេឱ្យសម្រាកពេទ្យអស់រយៈពេលដ៏យូរ ។ ការណ៍ដូចគ្នានេះ ទំនងជានឹងមានកើតឡើង បើសិនជាភាគីប្ដឹងឧទ្ធរណ៍នេះត្រូវការជាចាំបាច់នូវការសង្គ្រោះផ្នែកពេទ្យជាបន្ទាន់ណាមួយ ។

៤៤. ហេតុដូច្នេះ បណ្ដឹងឧទ្ធរណ៍នេះខកខានមិនបានធ្វើឱ្យករណីនេះស្ថិតនៅក្នុង ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ។

## ៥. សេចក្ដីសន្និដ្ឋាន

៤៥. អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញាសូមស្នើឱ្យអង្គបុរេជំនុំជម្រះ បដិសេធបណ្ដឹងឧទ្ធរណ៍នេះចោល ។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
នៅថ្ងៃទី២២ ខែមករា ឆ្នាំ២០០៨
**សហព្រះរាជអាជ្ញា**

CO-PROSECUTORS * CO-PROCUREURS * ECCC * CETC

| | |
|---|---|
| **លោកស្រី ជា លាង** | **លោក** Robert PETIT |
| **សហព្រះរាជអាជ្ញា** | **សហព្រះរាជអាជ្ញា** |